WORLD BANK GROUP

# ក្របខ័ណ្ឌភាពជាដៃគូសម្រាប់ប្រទេសកម្ពុជា របស់ធនាគារពិភពលោក ឆ្នាំ ២០២៥-២០២៩

## របាយការណ៍សង្ខេបនៃកិច្ចពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ

## ថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០២៣

## សណ្ឋាគារហៃយ៉ាត់ រីជិនស៊ី រាជធានីភ្នំពេញ

កិច្ចពិគ្រោះយោបល់លើកទី ៤ ស្តីពីក្របខ័ណ្ឌភាពជាដៃគូប្រចាំប្រទេស (CPF) របស់ធនាគារពិភពលោក ត្រូវបានលើកស្នើឡើងសម្រាប់ឆ្នាំ ២០២៥-២០២៩ ជាមួយនឹងប្រទេសកម្ពុជាត្រូវ បានរៀបចំធ្វើឡើងកាលពីថ្ងៃ ១៤ ខែធ្នូ ឆ្នាំ ២០២៣ ដោយមានការចូលរួមពីតំណាងចំនួន ៣៤ នាក់ មកពីខេត្តចំនួន ១១៖ (១) ភ្នំពេញ (២) កណ្តាល (៣) ព្រៃវែង (៤) កំពង់ស្ពឺ (៥) កំពង់ឆ្នាំង (៦) ព្រះសីហនុ (៧) កំពត (៨) កែប (៩) កោះកុង (១០) ស្វាយរៀង និង (១១) តាកែវ។ អ្នកចូលរួមប្រមាណពាក់កណ្តាល គឺជាស្ត្រី។

**និដ្ឋភាពរួមទូទៅ៖**

កិច្ចពិគ្រោះយោបល់នេះ ចាប់ផ្តើមជាមួយនឹងសន្ទរកថាស្វាគមន៍របស់លោក Asad Yaqub នាយកគ្រប់គ្រង IFC ប្រចាំប្រទេសកម្ពុជា។ បន្ទាប់មក ឯកឧត្តម ឈួន សំរិទ្ធិ អគ្គនាយកនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ថ្លែងសន្ទរកថាបើក។

បន្ទាប់មក មន្ត្រីធនាគារពិភពលោកបានធ្វើបទបង្ហាញអំពីបញ្ហាប្រឈម និងឱកាសសម្រាប់កម្ពុជា ដូចដែលត្រូវបានរកឃើញនៅក្នុងការវិភាគជាប្រព័ន្ធលើស្ថានភាពរបស់ប្រទេស ដែលធ្វើឡើងដោយធនាគារពិភពលោក រួមនឹងការធ្វើបទបង្ហាញពីក្របខ័ណ្ឌភាពជាដៃគូដែលត្រូវបានស្នើឡើង។ លោកអ្នកអាចចូលមើលឯកសារទាំងនេះតាមរយៈគេហទំព័រកិច្ចពិគ្រោះយោបល់ស្តីពី CPF ឆ្នាំ ២០២៥-២០២៩ សម្រាប់ប្រទេសកម្ពុជា។

អ្នកចូលរួមត្រូវបានបែងចែកជាក្រុម ដើម្បីពិភាក្សាពីលទ្ធផលកម្រិតខ្ពស់ ដោយត្រូវឆ្លើយសំណួរចំនួន ៤ – ខាងក្រោមនេះ គឺជាការបូកសរុបការឆ្លើយតប ដែលទទួលបានពីការពិភាក្សាក្រុមនេះ៖

| |
|---|
| **សំណួរទី ១៖ តើមានបញ្ហាធំៗជាងគេចំនួន ៣ អ្វីខ្លះ ដែលក្រុមធនាគារពិភពលោក (WBG) គួរផ្តោតការយកចិត្តទុកដាក់នៅក្នុងរយៈពេល ៤-៥ ឆ្នាំបន្ទាប់?** |
| **លទ្ធផលកម្រិតខ្ពស់ទី ១** – អ្នកចូលរួមដែលធ្វើការពិភាក្សាពីលទ្ធផលកម្រិតខ្ពស់លើកទី ១ បានកត់សម្គាល់ថា បញ្ហាសុខភាព និងអាហារូបត្ថម្ភ ក្នុងរយៈពេល ១០០០ ថ្ងៃដំបូងនៃជីវិតរបស់កុមារ នៅតែជាការងារដ៏សំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងប្រទេសកម្ពុជា។ អ្នកចូលរួមបានលើកស្នើបញ្ហាធំៗមួយចំនួន ដើម្បីឱ្យធនាគារ |

ពិភពលោកផ្តល់ការគាំទ្រនោះ គឺ ការបង្កើនគុណភាព បរិមាណ និងប្រេវ៉ាឡង់នៃសេវាថែទាំសុខភាព និងការផ្គត់ផ្គង់បរិក្ខារវេជ្ជសាស្ត្រនៅតាមតំបន់ជនបទ និងដាច់ស្រយាល។ អ្នកចូលរួមបានលើកស្នើថា បញ្ហានេះមានសារៈសំខាន់ និងចាំបាច់ ដើម្បីកសាងការជឿទុកចិត្តរបស់សហគមន៍ និងការបង្កើនការប្រើប្រាស់សេវាសុខភាព។ អ្នកចូលរួមក៏បានលើកឡើងផងដែរថា ការគាំទ្រដល់ការផ្សព្វផ្សាយព័ត៌មាន និងការអប់រំអំពីសុខភាព នឹងជួយលើកកម្ពស់លទ្ធផលសុខភាពនៅថ្នាក់ក្រោមជាតិ។ ពាក់ព័ន្ធនឹងការទទួលបានសេវាថែទាំសុខភាពវិញ អ្នកចូលរួមបានលើកស្នើឱ្យមានការពង្រីកវិសាលភាពគ្របដណ្តប់នៃប៉ុស្តិ៍សុខភាព ជាពិសេស នៅតាមសហគមន៍ជនបទ និងដាច់ស្រយាល។

ពាក់ព័ន្ធនឹងការអប់រំវិញ អ្នកចូលរួមបានកត់សម្គាល់ពីសារៈសំខាន់នៃការលើកកម្ពស់ការគ្រប់គ្រងធនធានមនុស្ស ជាពិសេស ការជ្រើសរើសគ្រូពីសហគមន៍ផ្ទាល់ ដើម្បីធានាឱ្យមានការផ្តល់សេវាឱ្យបានជាប់លាប់។ អ្នកចូលរួមក៏បានសំណូមពរឱ្យមានការផ្តល់ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដល់គ្រូបង្រៀន និងការបង្កើនប្រាក់លើកទឹកចិត្តសម្រាប់ការពង្រាយគ្រូទៅតាមទីតាំងដាច់ស្រយាល ដើម្បីសម្រេចលទ្ធផលអប់រំកាន់តែប្រសើរនៅកម្ពុជា។

**លទ្ធផលកម្រិតខ្ពស់ទី ២** - អ្នកចូលរួមបានចាត់ទុកហេដ្ឋារចនាសម្ព័ន្ធឌីជីថល ថាមពល ផ្គត់ផ្គង់ទឹកស្អាត និងគមនាគមន៍នៅថ្នាក់ក្រោមជាតិថាជាបញ្ហាគន្លឹះ ដែលធនាគារពិភពលោកអាចផ្តោតការយកចិត្តទុកដាក់ ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងការបង្កើតការងារនៅតាមបណ្តាខេត្ត។ អ្នកចូលរួមបានកត់សម្គាល់ពីសារៈសំខាន់នៃសេដ្ឋកិច្ចឌីជីថល ហើយក្នុងពេលទន្ទឹមគ្នា ជំរុញឱ្យមានការគាំទ្រ ដល់ការកាត់បន្ថយចំណាយថាមពល និងពង្រីកការតភ្ជាប់ទំនាក់ទំនងនៅក្នុងតំបន់ ដើម្បីទាក់ទាញការវិនិយោគ និងបង្កើនផលិតកម្ម រួមនឹងការកែលម្អការភ្ជាប់ទំនាក់ទំនងនៅក្នុងតំបន់ ក្នុងគោលបំណងជំរុញគម្រោងវិនិយោគ និងការអភិវឌ្ឍវិស័យទេសចរណ៍ ដូចជាផលិតផលទេសចរណ៍ថ្មីៗ (ឧទាហរណ៍ ការផ្សងព្រេងក្រោមសមុទ្រ គម្រោងខ្សែរ៉ូតពីទីខ្ពស់ទៅកាន់ឆ្នេរកែបដែលស្ថិតនៅខាងក្រៅតំបន់ទេសចរណ៍ពេញនិយមបែបប្រពៃណីតាមតំបន់ឆ្នេរ ដូចជា ក្រុងព្រះសីហនុជាដើម)។ អ្នកចូលរួមទាំងនេះ ក៏បានលើកឡើងពីភាពចាំបាច់ដែលត្រូវផ្តល់ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព ដល់ថ្នាក់ក្រោមជាតិ ដ្បិតបច្ចុប្បន្ននេះ មានការផ្ទេរមុខងារកាន់តែច្រើនពីថ្នាក់ជាតិ។ ក្រុមនេះក៏បានលើកឡើងពីសារៈសំខាន់នៃកម្មវិធីរបស់ធនាគារពិភពលោក ក្នុងការបង្កើនលទ្ធភាពទទួលបានធនធានហិរញ្ញវត្ថុ ជាពិសេស ការផ្តល់កម្ចីការប្រាក់ទាប ដល់សហគ្រាសធុនតូច និងមធ្យមជាដើម។ ចុងក្រោយ ពាក់ព័ន្ធនឹងវិស័យកសិកម្ម អ្នកចូលរួមបានលើកស្នើឱ្យមានការពង្រីកទីផ្សារសម្រាប់កសិផលរបស់ពួកគេ (ដូចជា ទស្សនទានភូមិមួយ ផលិតផលមួយ ជាដើម) ដើម្បីជំរុញផលិតកម្មកសិកម្ម និងលើកកម្ពស់សន្តិសុខស្បៀង។

**លទ្ធផលកម្រិតខ្ពស់ទី ៣** – ពាក់ព័ន្ធនឹងបញ្ហាធំៗជាងគេចំនួន ៣ សម្រាប់ធនាគារពិភពលោក នៅពេលពិភាក្សាពីលទ្ធផលកម្រិតខ្ពស់ទី ៣ អ្នកចូលរួមបានលើកឡើងពីភាពចាំបាច់ក្នុងការបង្កើនសមត្ថភាពឌីជីថល ការបណ្តុះបណ្តាល និងការអភិវឌ្ឍជំនាញ ដើម្បីលើកកម្ពស់មូលធនមនុស្ស និងពង្រីកការផ្សព្វផ្សាយកសិកម្មឱ្យបានកាន់តែទូលំទូលាយ ការបង្កើនសហគមន៍កសិកម្ម (ដោយមានការផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ និងការ

ភ្ជាប់ទំនាក់ទំនងទីផ្សារ) និងការរៀបចំសម្រិតសម្រាំងការបណ្តុះបណ្តាល ដែលត្រូវធ្វើទន្ទឹមគ្នានឹងការស្វែងរកទីផ្សារនាំចេញថ្មីៗសម្រាប់កសិផល។ អ្នកចូលរួមក៏បានគូសបញ្ជាក់ពីភាពចាំបាច់ក្នុងការលើកកម្ពស់លទ្ធភាពទទួលបានឥណទានប្រកបដោយបរិយាបន្នផងដែរ។

ក្រុមទី ៣ បានលើកឡើងជាពិសេសពីភាពចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋាន អមនឹងការពង្រឹងជំនាញដល់អាជ្ញាធរមូលដ្ឋាន តាមរយៈការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (D&D)។ អ្វីដែលជាទីចាប់អារម្មណ៍ពិសេស គឺការផ្តល់ជំនួយដល់ការរៀបចំថវិកា និងការកំណត់អាទិភាព ដើម្បីអាចបែងចែកថវិកាខេត្តដែលមានកម្រិត ឱ្យកាន់តែមានប្រសិទ្ធភាព និងចំអាទិភាព។

ការកែទម្រង់ D&D គឺជាអាទិភាពសម្រាប់ក្រុមនេះ ហើយក្រុមនេះបានលើកស្នើឱ្យមានការគាំទ្រដល់ការពង្រឹងស្ថាប័ន ដើម្បីជួយដល់រដ្ឋាភិបាលក្នុងការសម្រេចគោលដៅនៃកំណែទម្រង់នេះ ដូចជា ការធ្វើប្រតិភូកម្មអំណាចដល់ថ្នាក់ក្រោមជាតិជាដើម។

ចុងក្រោយ ក្រុមនេះបានលើកស្នើឱ្យមានការបញ្ជ្រាបយេនឌ័រ និងអាកាសធាតុទៅក្នុងការងាររបស់រដ្ឋបាលខេត្ត និងពង្រីកការគាំទ្ររបស់ធនាគារពិភពលោក ដល់ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការគាំទ្រដល់ការបង្កើនឌីជីថលូបនីយកម្មនៅថ្នាក់ខេត្ត។

**សំណួរទី ២៖ ថាតើធនាគារពិភពលោក គួរកាត់បន្ថយសកម្មភាពអ្វីខ្លះនៅក្នុងប្រទេសកម្ពុជា បើគិតពីឧត្តមភាពប្រកួតប្រជែងរបស់ធនាគារពិភពលោក?**

**លទ្ធផលកម្រិតខ្ពស់ទី ១** – អ្នកចូលរួមពុំបានលើកអនុសាសន៍អំពីកាត់បន្ថយអន្តរាគមន៍របស់ធនាគារពិភពលោកឡើយ ប៉ុន្តែបានលើកឡើងឱកាសដែលអាចមាន ដើម្បីពង្រីកអន្តរាគមន៍នានារបស់ធនាគារពិភពលោកបន្ថែមទៀត។

**លទ្ធផលកម្រិតខ្ពស់ទី ២** – អ្នកចូលរួមបានលើកឡើងថា ពួកគេចង់ឃើញគម្រោងដែលទទួលបានហិរញ្ញប្បទានពីធនាគារពិភពលោក មានវិធាន និងនីតិវិធីមិនសូវស្មុគស្មាញ ជាពិសេស នៅដំណាក់កាលរៀបចំគម្រោង (ការសិក្សាសមិទ្ធលទ្ធភាពសម្រាប់គម្រោងធនាគារពិភពលោកត្រូវការពេលយូរ) ដើម្បីពន្លឿនការអនុវត្តគម្រោង និងអាចទទួលបានផលជះជាវិជ្ជមាន និងអត្ថប្រយោជន៍ភ្លាមៗពីគម្រោង និងការគាំទ្រនានា ក្រោមហិរញ្ញប្បទានរបស់ធនាគារពិភពលោក។

**លទ្ធផលកម្រិតខ្ពស់ទី ៣** – អ្នកចូលរួមបានវាយតម្លៃខ្ពស់ចំពោះការផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុរបស់ធនាគារពិភពលោក និងស្នើឱ្យធនាគារពិភពលោកបន្តបន្ស៊ីគម្រោងនានាឱ្យស្របតាមកំណែទម្រង់របស់រដ្ឋាភិបាល និងមិនត្រូវធ្វើឱ្យរាំងស្ទះដល់កិច្ចខិតខំប្រឹងប្រែងវិមជ្ឈការ និងវិសហមជ្ឈការរបស់រដ្ឋាភិបាលឡើយ។

**សំណួរទី ៣៖ តើអ្នកយល់ឃើញយ៉ាងដូចម្តេចខ្លះ អំពីលទ្ធផលកម្រិតខ្ពស់ និងគោលដៅដែលត្រូវបានដាក់ចេញ សម្រាប់ក្របខ័ណ្ឌ CPF នេះ?**

**អ្នកចូលរួមទាំងអស់** សុទ្ធតែបានឯកភាពជាមួយនឹងលទ្ធផលកម្រិតខ្ពស់ និងគោលដៅនានា។

**សំណួរទី ៤៖ តើធនាគារពិភពលោក អាចឆ្លើយតបចំពោះបញ្ហាប្រឈមឆ្លងវិស័យខាងក្រោមឱ្យបានកាន់តែប្រសើរដោយរបៀបណា៖**

- **ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ**
- **អភិបាលកិច្ច និងសមត្ថភាពស្ថាប័ន**
- **សមភាពយេនឌ័រ និងបរិយាបន្ន**

**លទ្ធផលកម្រិតខ្ពស់ទី ១** – ក្រុមដែលពិភាក្សាអំពីលទ្ធផលកម្រិតខ្ពស់ទី ១ បានសំណូមពរឱ្យធនាគារពិភពលោកបង្កើនភាពធន់នឹងអាកាសធាតុនៃហេដ្ឋារចនាសម្ព័ន្ធនានា ដើម្បីទប់ទល់ជាមួយគ្រោះទឹកជំនន់កាន់តែប្រសើរ – ឧទាហរណ៍ ការសាងសង់ប្រព័ន្ធលូបង្ហូរទឹកឱ្យកាន់តែសមស្រប និងការពង្រឹងយន្តការផ្តល់សេវាដែលកំពុងមានស្រាប់ឱ្យកាន់តែមានភាពទាក់ទាញ និងទាន់ពេលវេលា។ ពាក់ព័ន្ធនឹងអភិបាលកិច្ចវិញ អ្នកឆ្លើយតបបានសំណូមពរឱ្យមានការបង្កើនការយកចិត្តទុកដាក់លើការគ្រប់គ្រងធនធានមនុស្សនៅក្នុងវិស័យសាធារណៈ និងបង្កើនការគាំទ្រផ្នែកឌីជីថលដល់រដ្ឋបាល និងយន្តការថ្នាក់ក្រោមជាតិ ដើម្បីបន្តអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ចុងក្រោយ អ្នកចូលរួមបានលើកស្នើឱ្យមានការគាំទ្រ និងការបណ្តុះបណ្តាល និងការផ្តល់ជំនួយ សម្រាប់វិស័យសុខភាព និងអប់រំ។ ពួកគាត់ក៏បានលើកស្នើឱ្យមានការលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រីផងដែរ។

**លទ្ធផលកម្រិតខ្ពស់ទី ២** – អ្នកចូលរួមបានគូសបញ្ជាក់ពីភាពចាំបាច់ ក្នុងការបង្កើនការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ សំដៅកសាងសមត្ថភាពដែលពាក់ព័ន្ធនឹងអាកាសធាតុនៅថ្នាក់ខេត្ត។ អ្នកចូលរួមបានលើកស្នើឱ្យមានការអភិវឌ្ឍសមត្ថភាព និងការផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ ដើម្បីអាចឆ្លើយតបចំពោះអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រកាន់តែប្រសើរ ជាពិសេស អំពើហិង្សាចំពោះស្ត្រី និងកុមារនៅថ្នាក់ក្រោមជាតិ។ អ្នកចូលរួមក៏សំណូមពរឱ្យរាល់គម្រោងទាំងអស់ដែលទទួលបានហិរញ្ញប្បទានពីធនាគារពិភពលោក បញ្ចូលការប្រែប្រួលអាកាសធាតុ អភិបាលកិច្ច និងការកសាងសមត្ថភាពស្ថាប័ន ព្រមទាំងទិដ្ឋភាពយេនឌ័រ។ ចុងក្រោយ អ្នកចូលរួមបានស្នើឱ្យការបណ្តុះបណ្តាល និងការអភិវឌ្ឍនានា ត្រូវទាញប្រយោជន៍ពីការវិភាគដែលធ្វើឡើងដោយធនាគារពិភពលោក ដែលអាចមានលក្ខណៈបច្ចេកទេស និងពិបាកយល់។

**លទ្ធផលកម្រិតខ្ពស់ទី ៣** – អ្នកចូលរួមបានលើកឡើងពីភាពចាំបាច់ ដើម្បីបង្កើនការចូលរួមសហការ និងការផ្តល់អំណាចធ្វើសេចក្តីសម្រេចចិត្តដល់ស្ត្រី ក្រុមដែលមានឱកាសតិចតួច និងក្រុមងាយរងគ្រោះ។ មានការលើកស្នើថា ដើម្បីសម្រេចគោលដៅនេះ ចាំបាច់ត្រូវមានការពង្រីកការផ្សព្វផ្សាយព័ត៌មាន តាមរយៈអាជ្ញាធរមូលដ្ឋាន ប្រេកឌីជីថល និងកិច្ចប្រជុំនានាជាដើម។ អ្នកចូលរួមបានបន្ថែមទៀតថា ដើម្បីជំរុញបរិយាបន្នឱ្យបានពេញលេញ ស្ត្រី ជនមានពិការភាព និងយុវជន ចាំបាច់ត្រូវអាចលើកឡើងពីបញ្ហាប្រឈម និងក្តីបារម្ភនានារបស់ពួកគេ ក៏ដូច

ជាចូលរួមក្នុងកិច្ចពិគ្រោះយោបល់អំពីការអភិវឌ្ឍប្រកបដោយអត្ថន័យ។ ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈម ពាក់ព័ន្ធនឹងអាកាសធាតុដែលមានលក្ខណៈឆ្លងវិស័យ អ្នកចូលរួមបានចាត់ទុកហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុ ថាជាឱកាសដ៏សំខាន់មួយ។